# លិខិតស្ដីអំពីការឆែកពិនិត្យជាបន្តនៅទិវា Nitbusters

## Nitbusters Day follow up letter

ឈ្មោះសិស្ស ______________________ ថ្នាក់ / ក្រុម ______________

Child's name Class/Group

ជូនចំពោះមាតាបិតា / អ្នកថែទាំ

កូនរបស់លោកអ្នកត្រូវបានគេឆែកពិនិត្យចៃក្បាល។ លទ្ធផលនៃការឆែកពិនិត្យមានបង្ហាញខាងក្រោមនេះ។

- ☐ គេពុំរកឃើញចៃក្បាលឡើយ។
  No head lice were found.
- ☐ គេរកឃើញពងចៃ។
  Nits (eggs) were found.
- ☐ គេរកឃើញចៃ និងពងចៃ។
  Head lice and nits (eggs) were found.

ប្រសិនបើកូនរបស់លោកអ្នកមានចៃ ឬពងចៃ Nitbusters ស្នើសុំឲ្យលោកអ្នកព្យាបាលចៃក្បាលកូនរបស់លោកអ្នក ហើយបន្តការឆែកពិនិត្យពងចៃ ឬចៃរៀងរាល់ពីថ្ងៃម្ដង។ សន្លឹកព័ត៌មានដែលភ្ជាប់មកជាមួយនេះ រៀបរាប់អំពីជម្រើសនៃការព្យាបាលមួយចំនួន។

ក្នុងនាមនៃកម្មវិធី Nitbusters យើងខ្ញុំសូមថ្លែងអំណរគុណលោកអ្នកដែលបានអនុញ្ញាតឲ្យកូនរបស់លោកអ្នកចូលរួមក្នុងទិវា Nitbusters។ សាលារៀនរបស់យើងឥឡូវនេះមានក្រុម Nitbusters មួយដែលបានទទួលការហ្វឹកហ្វឺន។ ក្រុមដែលបានទទួលការហ្វឹកហ្វឺនរបស់យើងអាចរៀបចំឲ្យមានទិវា Nitbusters ជាបន្ថែមនៅតាមសាលារៀន ប្រសិនបើមានសេចក្ដីត្រូវការ។ ប្រសិនបើលោកអ្នកមានសំណួរណាមួយស្ដីអំពីកម្មវិធីនេះ ឬលោកអ្នកមានបំណងស្ម័គ្រចិត្តជួយនៅក្នុងទិវា Nitbusters លើកក្រោយនេះ សូមទាក់ទងមកនាយកសាលា។

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយលោកអ្នកទាក់ទងមកនាយកសាលា សូមទូរស័ព្ទទៅសេវាអ្នកបកប្រែភាសាតាមទូរស័ព្ទលេខ 131 450 រួចស្នើសុំអ្នកបកប្រែភាសារបស់លោកអ្នកមួយរូប។ អ្នកប្រតិបត្តិការទូរស័ព្ទនឹងរៀបចំឲ្យមានអ្នកបកប្រែភាសាម្នាក់នៅតាមទូរស័ព្ទ ដើម្បីជួយលោកអ្នកនៅក្នុងការសន្ទនារបស់លោកអ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីលោកអ្នកឡើយ។

ព័ត៌មាននេះសំអាងលើព័ត៌មានដែលបានផ្ដល់នៅតាមវិបសាយរបស់ក្រសួងសុខាភិបាលរដ្ឋ NSW ស្ដីអំពី Nitbusters។